# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣១ អនក្រ.បក

# អនុក្រឹត្យ
ស្តីពី
**ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.១៦៤ ហិកតា**
**ស្ថិតនៅក្នុងភូមិសាស្រ្ត ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ**

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**មាត្រា១:**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ៦.១៦៤(ប្រាំមួយពាន់មួយរយហុកសិបបួន)ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំពង្រ និងឃុំចុងកាល់ ខេត្តឧត្តរមានជ័យ ដើម្បីធ្វើការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម(អំពៅ) ដំណាំផ្សេងៗ និងសាងសង់រោងចក្រកែច្នៃស្ករអំពៅ ដូចមាននៅក្នុងផែនទី និងនិយាមការចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០០៩ របស់អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ ដែលភ្ជាប់ជាមួយនឹងលិខិតលេខ ៩០ដនស/អវទ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០០៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២:**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣:**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ




| ក្បាលដី | ទំហំ គិតជាហិកតា |
|---|---|
| C01 | 5,809.38 |
| C02 | 340.26 |
| C03 | 15.19 |
| សរុប | 6,164.83 |

Projection UTM, zon 48 N Datum WGS 84

| ID | Northing | Easting |
|---|---|---|
| **C01** | | |
| 1 | 1559822.051 | 364576.816 |
| 2 | 1557454.791 | 364577.161 |
| 3 | 1557212.760 | 364335.140 |
| 4 | 1556962.760 | 364435.140 |
| 5 | 1556130.590 | 363283.364 |
| 6 | 1556325.062 | 362275.861 |
| 7 | 1555124.360 | 362277.476 |
| 8 | 1555407.684 | 363488.961 |
| 9 | 1553353.647 | 362806.105 |
| 10 | 1551757.247 | 360390.697 |
| 11 | 1551755.099 | 359363.763 |
| 12 | 1550583.512 | 359421.376 |
| 16 | 1550400.062 | 358700.808 |
| 17 | 1550326.398 | 358339.410 |
| 18 | 1550325.671 | 357275.372 |
| 19 | 1549749.106 | 357560.613 |
| 24 | 1547710.964 | 354575.456 |
| 25 | 1548324.034 | 354575.675 |
| 26 | 1555477.603 | 354590.323 |
| 30 | 1559821.668 | 359430.787 |
| 31 | 1555474.661 | 359427.398 |
| **C02** | | |
| 20 | 1549698.228 | 357585.764 |
| 21 | 1547957.449 | 358446.988 |
| 22 | 1547586.721 | 354575.414 |
| 23 | 1547667.483 | 354575.443 |
| **C03** | | |
| 13 | 1550551.905 | 359422.930 |
| 14 | 1550216.297 | 359439.434 |
| 15 | 1550378.100 | 358744.525 |

បានឃើញ និង ឯកភាព

ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៩

បានពិនិត្យត្រឹមត្រូវ

ភ្នំពេញ ថ្ងៃទី ... ខែ មករា ឆ្នាំ ២០០៩

ប្រធាននាយកដ្ឋានបច្ចេកទេស

ភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩

ប្រធានក្រុមវាស់វែង